**សេចក្ដីថ្លែងការណ៍បន្ទាន់**

## កម្ពុជា: គុណវិបត្តិនៃការដាក់ចេញ
## នូវសេចក្ដីព្រាងច្បាប់ស្ដីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

*សេចក្ដីពង្រាងច្បាប់លើកទីពីរ មិនបានពិចារណាលើការព្រួយបារម្ភនានានៃ ក្រុមសិទ្ធិមនុស្សឡើយ ។*

(បាងកក ថ្ងៃទី៧ ខែមេសា ឆ្នាំ២០១១) អង្គការឃ្លាំមើលសិទ្ធិមនុស្ស អង្គការលើកលែងទោសអន្តរជាតិ អង្គការវេទិកាអាស៊ី អង្គការឃ្លាំមើលបរិស្ថានពិភពលោក សម្ព័ន្ធសារព័ត៌មានអាស៊ីអាគ្នេយ៍ អង្គការអ្នកការពារសិទ្ធិជួរមុខ សហព័ន្ធអន្តរជាតិដើម្បីសិទ្ធិមនុស្ស និងអង្គការប្រឆាំងទារុណកម្មពិភពលោក ដែលយើងទាំងអស់គ្នាបំពេញការងារក្នុងក្របខណ្ឌនៃជាអ្នកសង្កេតការណ៍ ដើម្បីការពារអ្នកការពារសិទ្ធិមនុស្ស សូមប្រកាសនៅថ្ងៃនេះថា ប្រទេសកម្ពុជាបានចេញសេចក្ដីព្រាងច្បាប់មួយ ដែលដាក់កំរិតដល់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល (NGOs) គួរតែបោះបង់ចោល ដោយហេតុថាច្បាប់នោះ នឹងធ្វើឲ្យចុះខ្សោយទៅៗ ជាជាងលើកកម្ពស់សង្គមស៊ីវិលនៅក្នុងប្រទេសនេះ។

កាលពីថ្ងៃទី៦ ខែមេសាឆ្នាំ២០១១ អង្គការអន្តរជាតិដែលកំពុងប្រតិបត្តិការណ៍នៅក្នុងប្រទេសកម្ពុជា ចំនួន៦២អង្គការ បានអំពាវនាវដល់ប្រទេសនៃម្ចាស់ជំនួយនានា ដាក់ចេញនូវសេចក្ដីថ្លែងការណ៍ជាសាធារណៈ និងដាច់ដោយឡែកមួយយ៉ាងម៉ឹងម៉ាត់ ប្រឆាំងទៅនឹងការអនុម័តច្បាប់នេះ ដែលនឹងបង្កនូវការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់សង្គមស៊ីវិល នៅក្នុង

ប្រទេសនេះនាពេលអនាគត។

លោកប្រេដ អាដាម នាយកអង្គការឃ្លាំមើលសិទ្ធិមនុស្សប្រចាំទ្វីបអាស៊ី បានធ្វើការកត់សំគាល់ថា សេចក្តីព្រាងច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ដែលបានព្រាងមកនេះ អាចត្រូវបានគេយកមកប្រើប្រាស់ យ៉ាងងាយស្រួល ដើម្បីបដិសេធមិនឲ្យមានការចុះបញ្ជី ឬ បិទអង្គការនានាដែលបម្រើផលប្រយោជន៍សាធារណៈ។ រយៈពេលជាង២០ឆ្នាំកន្លងមកនេះ ការរីកវឌ្ឍនៃសង្គមស៊ីវិល គឺជាសមិទ្ធិផលមួយ ក្នុងចំណោមសមិទ្ធិផលដ៏ទៃទៀតរបស់កម្ពុជា។ តែផ្ទុយទៅវិញវត្តមាននៃច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល គឺជាការគំរាមកំហែងដល់វឌ្ឍនៈភាពនេះទៅវិញ។

លោក យែប ស្វីសេង នាយកប្រតិបត្តិអង្គការវេទិកាអាស៊ី បានលើកឡើងថា នៅពេលសេចក្តីពង្រាងច្បាប់នេះ ត្រូវបានផ្សព្វផ្សាយជាលើកដំបូងកាលពីខែធ្នូ ឆ្នាំ២០១០ សង្គមស៊ីវិល បានលើកឡើងនូវការព្រួយបារម្ភថា សេចក្តីពង្រាងច្បាប់នេះ នឹងផ្តល់ភាពងាយស្រួលដល់ការរំលោភបំពានពី សំណាក់មន្ត្រីនានាចាប់ពីថ្នាក់ជាតិ ថ្នាក់ខេត្តរហូតដល់ឃុំ នៅពេលដែលពួកគេខិតខំបំបិទសម្លេងរិៈគន់នៃសង្គមស៊ីវិល។ កើតចេញពីការភ័យខ្លាចទាំងអស់នេះ ការពិនិត្យមើលឡើងវិញនៃសេចក្តីព្រាងច្បាប់នេះ រាជរដ្ឋាភិបាលបានធ្វើឲ្យស្ថានភាពអាក្រក់ កាន់តែធ្ងន់ធ្ងរឡើងៗ។ មាត្រាដែលកែសំរួលថ្មីៗ បង្ហាញពីភាពងាយស្រួលក្នុងការបដិសេធ ឬពន្យាពេលក្នុងការចុះបញ្ជី ចំពោះអង្គការណាដែលគេយល់ឃើញ ថាបានរិៈគន់រដ្ឋាភិបាល នឹងបណ្តាលឲ្យរដ្ឋាភិបាលគៀបសង្កត់មួយនេះ កាន់តែរឹតត្បិតដល់សកម្មភាពរបស់សង្គមស៊ីវិលកាន់តែខ្លាំងឡើងៗ។

បញ្ហាចម្បងៗនៃសេចក្តីព្រាងច្បាប់គឺ:

- **ការចុះបញ្ជីរក្សាទុកជាកាតព្វកិច្ច បើទោះបីមានការអំពាវនាវម្តងហើយម្តងទៀត ឲ្យធ្វើតាមបទដ្ឋានអន្តរជាតិដែលថា ការចុះបញ្ជីធ្វើឡើងតាមការស្ម័គ្រចិត្ត។** សមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលមិនបានចុះបញ្ជី ត្រូវបានហាមប្រាមមិនឲ្យប្រតិបត្តិការ។ ការចុះបញ្ជី ដែលមានលក្ខណៈជាកាតព្វកិច្ច ជាការដាក់កំរិតដល់សិទ្ធិសេរីភាព ក្នុងការបង្កើត

សមាគម ដែលបានធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា ២២ នៃ អនុសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ដែលប្រទេសកម្ពុជា គឺជាប្រទេសហត្ថលេខី។

- **ភាពច្រើនហួសប្រមាណនៃការចុះបញ្ជី និងដំណើការនៃការផ្តល់របាយការណ៍ ជាការប្រឈម ដល់អង្គការតូចៗ សមាគម និងបណ្តាញសហគម ក្នុងការដាក់វិន័យ និងបណ្តឹងព្រហ្មទណ្ឌ ដែលបញ្ហានេះគឺនៅតែរក្សាទុកក្នុងសេចក្តីព្រាងច្បាប់លើកទីពីរនេះ។** ឃ្លាបន្ថែមថ្មីនេះ ធ្វើឲ្យរដ្ឋាភិបាលអាចលុបឈ្មោះអង្គការណាមួយ ចេញពីបញ្ជីដែលបានអនុញ្ញាតិរួចហើយ ប្រសិនអង្គការនោះខកខានក្នុងការដាក់ជូននូវលិខិត ប្រកាសគណនីធនាគារ ក្នុងអំឡុង៣០ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលលិខិតសំរេចចុះបញ្ជី។ ការសំរេចដោយគ្មានការបើកប្តឹងតវ៉ានេះ នឹងជះឥទ្ធិពលអវិជ្ជមានដល់ក្រុមដែលប្រតិបត្តិការ នៅកំរិតថ្នាក់ឃុំ និងតាមសហគម ដែលក្រុមទាំងនេះជារឿយៗ ខ្វះធនធានក្នុងការប្រតិបត្តិលើលិខិតស្នាម ដែលមានលក្ខណៈការិយាល័យធិបតេយ្យដ៏ស្មុគ្រស្មាញ។ ពួកគេទាំងនោះងាយនឹងរងគ្រោះផងដែរ លើការចោទប្រកាន់ដោយតុលាការ ចំពោះការអនុវត្តសកម្មភាពផ្លូវច្បាប់ ដែលមិនមានលក្ខណៈត្រឹមត្រូវតាមច្បាប់។
- **ការព្រួយបារម្ភអំពីការខ្វះនូវការការពារផ្លូវច្បាប់ យន្តការត្រួតពិនិត្យប្រព័ន្ធតុលាការ ឬសិទ្ធិក្នុងការប្តឹងតវ៉ា មិនត្រូវបានបង្ហាញចេញ និងការព្រួយបារម្ភដោយយោងលើ ភាពស្រពិចស្រពិលនៃការផ្តល់និយមន័យ នៅក្នុងសេចក្តីព្រាងដំបូងមិនត្រូវបានដោះស្រាយ។** ការអះអាង ដោយប្រើពាក្យ "ប្តឹងតវ៉ា" នៅក្នុងពង្រាងដំបូង បង្ហាញពីសិទ្ធិក្នុងការឆ្លើយតបមានកំរិត ដែលអ្នកដាក់ពាក្យសុំអាចកែទៅជាពាក្យ "ភាពមិនលេញលេញ" នៅក្នុងពាក្យសុំរបស់ពួកគេ ប្រសិនបើវាត្រូវបានបដិសេធចោល។ ត្រង់នេះត្រូវបានដកចេញទាំងស្រុងក្នុងពង្រាង ទីពីរ។
- លោក ស៊ូហាយ ប៊េលហាសេន ប្រធានសម្ព័ន្ធអន្តរជាតិដើម្បីសិទ្ធិមនុស្ស បានមានប្រសាសាន៍ថា "គំរូនៃការគាបសង្កត់ ដែលត្រូវបានឃ្លាំមើល និងចងក្រងទុកនៅក្នុងប្រទេសកម្ពុជាអស់រយៈពេលជាងមួយទសវត្សរ៍កន្លងមកនេះ ផ្តល់ហេតុផលឲ្យយើងជឿបានថា ពង្រាងច្បាប់នេះ មានគោលបំណងតែមួយគត់ គឺរឹតបន្តឹងទៅលើសង្គមស៊ីវិល ដែលឯករាជ្យ តាមរយៈការ ចាប់ច្បាមរបស់រដ្ឋាភិបាល។"

- អង្គការនានាបានមានប្រសាសន៍ថា "រដ្ឋាភិបាលនៃប្រទេសកម្ពុជា បានបរាជ័យ ក្នុងការផ្តល់ចម្លើយគ្រប់គ្រាន់មួយចំពោះ មូលហេតុដែលថា ច្បាប់ថ្មីនេះមានភាពចាំបាច់ ដូចគ្នានឹងបទបញ្ជា និងច្បាប់ដែលមានស្រាប់ផ្សេងទៀតក្នុងការគ្រប់គ្រងសង្គមស៊ីវិល"។ ជាពិសេស អង្គការយើងខ្ញុំទាំងអស់មានជំនឿថា ការអនុម័តក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ គឺជាក្រប ខណ្ឌផ្លូវច្បាប់គ្រប់គ្រាន់មួយក្នុងការដាក់កំរិតទាំងស្ថាប័នស្វែងរកប្រាក់កម្រៃ និងមិនរកកម្រៃ ដោយផ្អែកលើការចុះបញ្ជីដោយស្ម័គ្រចិត្ត ដែលធ្វើឲ្យសេចក្តី ណែនាំ ច្បាប់ថ្មីនេះមិនចាំបាច់។
- លោក ស៊ីម៉ូន ថេឡើ នាយកអង្គការឃ្លាំមើលបរិស្ថានពិភពលោក បានមានប្រសាសន៍ ថា "ម្ចាស់ជំនួយអន្តរជាតិរបស់ប្រទេសកម្ពុជា បានចំណាយរាប់ពាន់លានដុល្លាអាមេរិកសម្រាប់កម្មវិធីអភិវឌ្ឍន៍ផ្សេងៗ ដើម្បីពង្រឹង និងកសាងសមត្ថភាពរបស់សង្គម ស៊ីវិលក្នុងប្រទេសកម្ពុជា។ ភាពប្រថុយប្រថាននៃការផ្តួចផ្តើមទាំងនេះ អាចធ្វើឲ្យគ្មានប្រសិទ្ធិភាពចំពោះច្បាប់ដែលបានស្នើឡើងនេះ។ ប្រសិនបើម្ចាស់ជំនួយចាំជួយ ចំណែករដ្ឋាភិបាលអនុម័តច្បាប់នេះ ពួកគេមិនអាចមានមនសិកាល្អក្នុងការធ្វើការដើម្បី ផលប្រយោជន៍នៃគោលដៅអភិវឌ្ឍន៍ប្រទេសកម្ពុជាឡើយ។"
- លោក អ៊ីរិក សុតាស លេខាធិការអង្គការប្រឆាំងទារុណកម្មពិភពលោក បានមានប្រសាសន៍ថា "យើងជំរុញយ៉ាងទទូចដល់រាជរដ្ឋាភិបាលកម្ពុជា ឲ្យបោះបង់ចោលពង្រាងច្បាប់នេះ និងធានាថា ច្បាប់ គោលនយោបាយ និងបទបញ្ជាទាំងអស់ដែលពាក់ព័ន្ធនឹងភាពចម្រុះ ប្រហែសរបស់សង្គមស៊ីវិលក្នុងប្រទេសកម្ពុជាត្រូវបានចែង និងអនុវត្តក្នុងបរិបទមួយដែលគោរពសិទ្ធិមនុស្ស និងអនុលោមតាមបទដ្ឋានអន្តរជាតិ។

## សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង

From Amnesty International: Donna Guest (London), + 44 207 413 5654 (office), + 44 7961 421541 (mobile), dguest@amnesty.org

From FIDH: Karine Appy (Paris), + 33-14-355-1412, + 33-14-355-9019, kappy@fidh.org; and Shiwei Ye (Bangkok): +66 2 275 4233, sye@fidh.org

From Forum Asia: Yap Swee-Seng (Bangkok), +66 81 8689178, yap@forum-asia.org

From Front Line Defenders: Jim Loughran (Dublin), +353 1 212 3750, jimloughran@frontlinedefenders.org

From Global Witness: George Boden (London), +44-207 492 5899, + 44-7808 767 134, gboden@globalwitness.org; and Oliver Courtney (London), +44-207 492 5848, + 44-7739 324 962, ocourtney@globalwitness.org

From Human Rights Watch: Brad Adams (London), +44-79-0872-8333, adamsb@hrw.org; Phil Robertson (Bangkok), +66-85-060-8406, robertp@hrw.org; and Sophie Richardson (Washington, DC), +1-917-721-7473, +1-202-612-4341, richars@hrw.org

From OMCT: Seynabou Benga (Geneva), + 41-22 809 49 39, sb@omct.org, Delphine Reculeau (Geneva), + 41-22 809 49 39, dr@omct.org

From SEAPA: Gayathry Venkiteswaran (Bangkok), +66-88-017-4810, gayathry@seapa.org